ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ..០១៣២/២៤.......ន. គ. ស /សរក.៧.

## សេចក្តីជូនដំណឹង

## ស្តីពី

## សំណើវិសោធនកម្មបន្ថែមទៅលើសេចក្តីព្រាងស្តង់ដា កំណែប្រែលើកទី ៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

និយ័តករគណនេយ្យនិងសវនកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា៖ នាខែមីនា ឆ្នាំ២០២៤ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និង អនុម័តលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយនូវសំណើវិសោធនកម្មបន្ថែមទៅលើសេចក្តីព្រាងស្តង់ដា កំណែប្រែលើកទី៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម និងសេចក្តីព្រាងស្តង់ដា (Exposure Draft) ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ។

សំណើផ្តល់មតិយោបល់ទៅលើវិសោធនកម្មបន្ថែមទៅលើសេចក្តីព្រាងនេះ នឹងផុតកំណត់ត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ ដូចនេះ ប្រសិនបើ ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅមានបំណងក្នុងការបញ្ចេញ មតិយោបល់លើសេចក្តីព្រាងនេះ សូមផ្ញើមតិយោបល់មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល៖ p.sopheacha@acar.gov.kh យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh។

អាស្រ័យហេតុនេះ សូម ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ជ្រាបជាព័ត៌មាន និងចូលរួមផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងវិសោធនកម្មនេះឱ្យបានទាន់ពេលវេលាកំណត់។

ថ្ងៃអង្គារ ១៤ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២៤

**និយ័តករគណនេយ្យនិងសវនកម្ម**

*Scan ដើម្បីទាញយកឯកសារ*

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111